# កំរិតដែលជនរងគ្រោះបន្ទោសទៅលើសហគមន៍ផ្ទះជួលនៅភ្នំពេញ

## ការរកឃើញពីការសិក្សាស្រាវជ្រាវដោយ អង្គការក្លាហាន អង្គការភីន និង អង្គការអសក ខែកុម្ភះ ឆ្នាំ២០១៩

សលាកបត្រព័ត៏មាន ៣/៤

### ទិន្នន័យទូទៅអំពីការរំលោភបំពានផ្លូវភេទ នៅទីសាធារណៈ




អ្នកឆ្លើយតប ៦០%
យល់ថាការរំលោភបំពាននេះកើតឡើងនៅក្បែរទីសាធារណៈ (តាមផ្លូវ និង តាមច្រកតូចៗ) ថ្វីត្បិតតែអាត្រានៃការកើតឡើង មានភាពខុសគ្នាឆ្ងាយ (២៦% បានឆ្លើយថាវាមិនសូវជាកើតឡើង ចំណែក ១៤%ទៀតឆ្លើយថាវាកើតឡើងយ៉ាងញឹកញាប់)។

ទិន្នន័យមតិស្ទាបស្ទង់គ្រួសារបានបង្ហាញថា
ភាពញឹកញាប់នៅការរំលោភបំពានផ្លូវភេទ នៅកន្លែងមួយ
វាអាស្រ័យលើទៅលើការគិតរបស់ប្រជាជនរស់នៅក្នុងតំបន់នោះទៅលើសុវត្ថិភាពក្នុងតំបន់។ ឧទាហរណ៍
ទីកន្លែងដែលមានភាគរយនៃការការរំលោភបំពានផ្លូវភេទខ្ពស់
ក៏អាចចាត់ទុកជាកន្លែងមួយដែលមិនមានសុវត្ថិភាពសម្រាប់ស្ត្រីនៅពេលយប់ផងដែរ។

> *“ស្ត្រីមានអារម្មណ៍ថាមិនមានសុវត្ថិភាពជាពិសេសនៅពេលយប់ពីព្រោះពួកគេត្រូវប្រើប្រាស់បង្គន់រួមគ្នា នៅជាន់មួយទៀត។”*
>
> ប្រធានសហគមន៏នៅតំបន់ច្រាំងចំរេះ

### របាយការណ៍ហានិភ័យនៃការអន្តរាគមន៏ពីអ្នកឈរមើល:

វាពិតជាគួរឲ្យកត់សម្គាល់ថា
មិតិទូទៅយល់ឃើញថាវាពិតជាមានភាពគ្រោះថ្នាក់ណាស់ជាពិសេសស្ត្រីនៅពេលដែលពួកគេព្យាយាមចូលជួយនៅក្នុងករណីអំពើហិង្សាយេនឌ័រដែលគេឃើញ។ ហានិភ័យពីការអន្តរាគមន៏ពីអ្នកឈរមើល
ត្រូវបានលើកឡើងក្នុងចម្លើយមួយចំនួន។ ជាក់ស្តែងស្ត្រីម្នាក់ត្រូវបានគេវាយដំបន្ទាប់ពីព្យាយាមជួយអ្នកជិតខាងដែលកំពុងត្រូវបានប្តីវាយ ។

> *“នៅក្នុងបន្ទប់ខ្ញុំ វាពិតជាគ្មានសុវត្ថិភាពទេ។ អ្នកប៉ុនប៉ងចាប់រំលោភ និងចោរលួច អាចចូលមកក្នុងបន្ទប់របស់យើង ដោយសារផ្ទះសង់មិនបានល្អ។”*
>
> បុរសម្នាក់បានលើកឡើងនៅក្នុងការប្រជុំពិភាក្សាក្រុមនៅតំបន់ជើងឯក

### ការយល់ដឹងអំពីករណីអំពីអំពើហិង្សា និងការរំលោភបំពានដែលកើតមានឡើងនៅក្នុងតំបន់ជុំវិញបន្ទប់ជួល

មនុស្សចំនួន ៤៨ នាក់(ស្មើនឹង ២៩%)
ដែលបានផ្តល់កិច្ចសម្ភាសន៏បានបង្ហាញថា
ពួកគាត់បានដឹងឬជួបជាក់ស្តែងនៅអំពើហឹង្សា ឬ
ការរំលោភបំពាននៅទីសាធារណៈជុំវិញបន្ទប់ជួល។
នេះតិចជាងចំនួនអ្នកដែលបានរាយការណ៍ថាឃើញអំពើហិង្សាក្នុងគ្រួសារ ១០ នាក់។

ដូច្នេះមានន័យថាបើទោះបីជាអ្នកជួលបន្ទប់មានការភ័យខ្លាចពីគ្រោះថ្នាក់ដែលបង្ករដោយជនចម្លែក (យោងតាម សលាកបត្រព័ត៏មាន ១)
ប៉ុន្តែជាក់ស្តែងពួកគេអាចនឹងឃើញអំពើហិង្សាក្នុងគ្រួសារនៅក្នុងសហគមន៏របស់គាត់ច្រើនជាងទៅវិញ។




*ការសិក្សានេះមានការស្ទង់មតិចំនួន 167 គ្រួសារការពិភាក្សាក្រុមចំនួន 6 និងការសម្ភាសអ្នកផ្តល់ព៌តមានសំខាន់ៗចំនួន 20 ។ សម្រាប់វិធីសាស្រ្តពេញលេញនិងការរកឃើញ អ្នកអាចរករបាយការណ៍តាមអ៊ីនធឺណែត www.klahaan.org/publications

ក្លាហាន klahaan brave · PEOPLE IN NEED CZECH REPUBLIC · UPWD · UNITED NATIONS HUMAN RIGHTS OFFICE OF THE HIGH COMMISSIONER Cambodia · EUROPEAN UNION